**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
------

# ពលរដ្ឋខ្មែរនៅប្រទេសអង់គ្លេស
# ប្រឆាំងការដាក់ទណ្ឌកម្មលើរាជរដ្ឋាភិបាលកម្ពុជា

------------

ពលរដ្ឋខ្មែរមួយចំនួននៅចក្រភពអង់គ្លេស កាលពីថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨ បានផ្ញើញត្តិចំនួនបីច្បាប់ដោយឡែកពីគ្នា ជូនលោកជំទាវ **តេរ៉េសា មេយ** (Theresa May) នាយករដ្ឋមន្ត្រីអង់គ្លេស ឯកឧត្តម **ចន ប៊ឺរខោវ** (John Bercow) ប្រធានសភាអង់គ្លេស និងឯកឧត្តម **បូរីស ចនសុន** (Boris Johnson) រដ្ឋមន្ត្រីការបរទេស និងកិច្ចការកុម្ម៉ុនវែលអង់គ្លេស សម្តែងការគាំទ្រចំពោះការថែរក្សាសន្តិភាព ស្ថិរភាព និងកិច្ចអភិវឌ្ឍនៅកម្ពុជា ហើយបានអំពាវនាវចក្រភពអង់គ្លេស កុំឱ្យដាក់ទណ្ឌកម្មណាមួយ និងកុំឱ្យគាំទ្រការដាក់ទណ្ឌកម្មដោយប្រទេសណាមួយមកលើរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ញត្តិដែលអត្ថបទដើមជាភាសាអង់គ្លេសភ្ជាប់ដោយហត្ថលេខារបស់ពលរដ្ឋខ្មែរ មានខ្លឹមសារសំខាន់ៗដូចខាងក្រោមនេះ៖

យើងខ្ញុំវាយតម្លៃខ្ពស់ ចំពោះការរួមចំណែករបស់រដ្ឋាភិបាលអង់គ្លេសក្នុងការអភិវឌ្ឍកម្ពុជា។ ដោយសារមានសន្តិភាព និងស្ថិរភាព កម្ពុជាសម្រេចបាននូវកំណើនសង្គម-សេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ ដែលមានកំណើន GDP ប្រចាំឆ្នាំជាមធ្យម ៧.៧% ក្នុងរយៈកាលពីរទសវត្សកន្លងមកនេះ។ កម្ពុជារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងមានកម្រិតអតិផរណាត្រឹម ៣.៨% ប៉ុណ្ណោះ នៅក្នុងឆ្នាំ២០១៧ ហើយអាត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី ៥៣.៥% នៅក្នុងឆ្នាំ២០០៤ មកត្រឹម ១៣.៥% នៅក្នុងឆ្នាំ២០១៤ ដែលបានធ្វើឲ្យកម្ពុជាឈានពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលថ្មីៗនេះ។

វិស័យឧស្សាហកម្មកាត់ដេរ និងស្បែកជើង បានបង្កើតឲ្យមានការងារជាង ៨០០,០០០កន្លែង ហើយប្រជាជនកម្ពុជារាប់លាននាក់ផ្សេងទៀតក៏បានទទួលផលប្រយោជន៍ពីលក្ខខណ្ឌអនុគ្រោះពន្ធ GSP/EBA/MFN។ ប្រជាជនកម្ពុជាធម្មតា ជាពិសេស គឺកម្មកររោងចក្រ និងកសិករ នឹងទទួលរងនូវផលប៉ះពាល់ខ្លាំងបំផុត ប្រសិនបើរដ្ឋាភិបាលអង់គ្លេសដាក់ទណ្ឌកម្មណាមួយមកលើកម្ពុជា។

សន្តិភាពដែលរកបានដោយលំបាក សន្តិសុខ ស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមដោយនិរន្តភាព កំពុងស្ថិតក្រោមការគំរាមកំហែងពីការរាំងស្ទះ និងការដាក់ទណ្ឌកម្ម ដែលអាចនឹងកើតមានឡើងដោយសារការលាបពណ៌រូបភាពអវិជ្ជមាននៃស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា និងការជម្រុញការដាក់ទណ្ឌកម្ម ទៅលើរាជរដ្ឋា

ភិបាលកម្ពុជាដែលបានចាត់វិធានការណ៍ស្របច្បាប់ ដើម្បីការពារអធិបតេយ្យភាពរបស់ប្រទេស និងបានឆ្លើយតបទៅនឹងការប៉ុនប៉ង ដែលអាចធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលម្តងទៀត។

អាស្រ័យហេតុនេះ យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលនៃចក្រភពអង់គ្លេស សូម ៖

- រក្សាទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគដែលផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមកជាមួយកម្ពុជា។
- កុំដាក់ទណ្ឌកម្មដោយផ្ទាល់ណាមួយ និង/ឬ ដាក់ការហ៊ុំព័ទ្ធសេដ្ឋកិច្ច និង/ឬ សូមកុំគាំទ្រដល់ការដាក់ទណ្ឌកម្ម ឬសកម្មភាពដាក់ទណ្ឌកម្មណាមួយ ដែលផ្តួចផ្តើមដោយប្រទេស/សម្ព័ន្ធមិត្ត ដៃគូពាណិជ្ជកម្មនានា ហើយនិងក្រុមណាមួយ ទៅលើប្រទេសកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់ក្រុមប្រឆាំងមួយក្តាប់តូច។
- គិតគូរដល់ផលវិបាកយូរអង្វែង ដែលអាចនឹងបន្សល់ទុកពីសកម្មភាពទាំងនេះ និងអាចធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលម្តងទៀត។
- បន្តពង្រីក និងពង្រឹងបន្ថែមទៀត នូវកិច្ចសហប្រតិបត្តិការដ៏ល្អ និងផ្តល់ការគាំទ្រជាបន្តដល់កម្ពុជា។

ដើម្បីជាសក្ខីភាព យើងខ្ញុំសូមផ្តិតមេដៃ/ចុះហត្ថលេខា ដូចខាងក្រោម ។

ធ្វើនៅចក្រភពអង់គ្លេស ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃ ព្រហស្បតិ៍ ១៥រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ, ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៨